# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៦៦៥ MIH / 2015

## ប្រកាស
## ស្តីពី
## ការកំណត់ទទួលស្គាល់ស្តង់ដារបន្ទាប់ គីឡូក្រាម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៤/៩៩០ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកំណត់ស្តង់ដារគោលជាតិគីឡូក្រាម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៨០ MIH/2014 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវិទ្យា សាស្ត្រមាត្រាសាស្ត្រ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ .—**

ត្រូវបានកំណត់ទទួលស្គាល់ស្តង់ដារបន្ទាប់គីឡូក្រាម ដែលត្រូវរក្សាទុកនៅនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) មានអត្តសញ្ញាណ ដូចខាងក្រោម ៖

| | | |
|---|---|---|
| លេខសម្គាល់ | : | ២៣៣០២០៤ |
| ទម្ងន់ | : | ១ (មួយ) គីឡូក្រាម |
| ផលិតនៅ | : | ប្រទេសអាឡឺម៉ង់ |
| ចំណាត់ថ្នាក់ | : | អឺសូន្យ (E0) |
| វត្ថុធាតុ | : | សំលោហធាតុពិសេសដែលមិនច្រេះ |

អត្តសញ្ញាណនៃស្តង់ដារបន្ទាប់ គីឡូក្រាម មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២ .—**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាន ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៥

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ចម ប្រសិទ្ធ

**កន្លែងទទួល ៖**
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានី ខេត្ត
- ដូចប្រការ២
- ឯកសារ កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

# ឧបសម្ព័ន្ធ

នៃប្រកាសលេខ ៨៦៩ MIH/2015 ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៥

## ស្តីពីការកំណត់ទទួលស្គាល់ស្តង់ដាបន្ទាប់ គីឡូក្រាម

### ស្តង់ដាបន្ទាប់គីឡូក្រាម ទម្ងន់ ១ គ.ក្រ ថ្នាក់ E0



### ប្រអប់សម្រាប់ថែរក្សាស្តង់ដាបន្ទាប់គីឡូក្រាមពេលបញ្ជូនទៅធ្វើព្យាសកម្ម




